**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខៈ ១០៦/១៨ ស.ណ.ក អ.ជ.ប.គ.ញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ អង្គារ ៦ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨

# របាយការណ៍
## ស្ដីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា និងទិសដៅការងារ ខែកញ្ញា ឆ្នាំ២០១៨

(ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ ដល់ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨)

នៅក្នុងខែសីហានេះ រាជរដ្ឋាភិបាលបាននិងកំពុងមមាញឹកក្នុងការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ កាលពីថ្ងៃទី២៩ ខែកក្កដា បានបញ្ចប់ទៅដោយជោគជ័យ ។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ** ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតែបន្តយកចិត្តទុកដាក់អនុវត្តនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ដើម្បីរួមចំណែកពង្រឹង និងរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងទប់ស្កាត់រាល់សកម្មភាពពាក់ព័ន្ធនឹងគ្រឿងញៀន ដោយប្រមូលផ្ដុំសមាសភាពពីគ្រប់មជ្ឈដ្ឋានអនុវត្តយ៉ាងសកម្មក្លៀវក្លាបន្ថែមពីលើការអនុវត្តផែនការជាតិ ៣ ឆ្នាំ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។ តាមរយៈការអនុវត្តផែនការយុទ្ធនាការ និងផែនការជាតិស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ដូចជាផែនការសកម្មភាពអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែកក្កដាកន្លងទៅ យើងបានកត់សម្គាល់ពីសភាពការណ៍គ្រឿងញៀន និងអនុវត្តការងារក្នុងខែសីហានេះ សម្រេចបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែសីហានេះ សកម្មភាពចរាចរដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ចូលមកកម្ពុជា នៅតែបន្តកើតមានគួរឱ្យព្រួយបារម្ភ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលយើងបានបង្ក្រាប កត់សម្គាល់ឃើញមាន ៧ ករណីធំៗ ដែលបង្ក្រាបដោយកម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន, កម្លាំងនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ រួមទាំងសមត្ថកិច្ចពាក់ព័ន្ធ ដែលក្នុងនោះធ្វើសកម្មភាពដោយ ៖

– ក្រុមឈ្មួញក្នុងតំបន់ មាន ៤ ករណី ដែលនាំគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជាតាមច្រកនៃបណ្ដាខេត្តនៅភាគឦសានប្រទេស ។ សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យ ៦នាក់ ក្នុងនោះជនជាតិខ្មែរ ៤នាក់ ជនជាតិចិន ១នាក់ និងជនជាតិឡាវ (សញ្ជាតិកាណាដា) ១នាក់ ចាប់យកគ្រឿងញៀនសរុបជិត ១៧ គ.ក្រ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website: www.nacd.gov.kh

– ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិមាន ៣ករណី ដែលធ្វើសកម្មភាពធ្វើតាមបញ្ញើប្រៃសណីយ៍ ។ សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យ ២នាក់ (ជនជាតិខ្មែរ ១នាក់, ចិន១នាក់) និងវត្ថុតាងអិចស្តាស៊ី (MDMA) សរុបជាង ១០២ គ.ក្រ ។

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធនឹងការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តជំរុញការអនុវត្តវិធានការផ្សព្វផ្សាយអប់រំ ដល់ក្រុមគោលដៅងាយរងគ្រោះ មានដូចជា ក្រុមពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា តាមរយៈការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ និងវេទិកាជួបជាមួយវិស័យឯកជន ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត។ ជាពិសេស ត្រូវបន្តបណ្តុះបណ្តាលជនបង្គោលឱ្យបានច្រើនបន្ថែមទៀត ដើម្បីពួកគាត់ជួយដល់យើងលើការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និង ការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និងឯកជន ក្នុងការទទួលជនរងគ្រោះដែលបញ្ជូនទៅទទួលយកសេវាព្យាបាល, បន្តពង្រឹងនិងពង្រីកសេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវបន្តការស្វែងរកមូលនិធិសមធម៌ ជូនដល់អ្នកញៀនគ្រឿងញៀនដែលទៅទទួលសេវាពិនិត្យនិងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់ទៅប្រើគ្រឿងញៀនឡើងវិញ និងបន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដោយផ្សារភ្ជាប់ជាមួយការងារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន **(BLO)**, មន្ត្រីអនុវត្តច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោលនៃកងយោធពលខេមរភូមិន្ទ ។ ទន្ទឹមនេះ ត្រូវបន្តពង្រឹងនីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន និងនីតិវិធីនៃការរឹបអូសទ្រព្យសម្បត្តិ ដើម្បីគណៈកម្មការការតាមដានការប្រមូលការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុឱ្យទាន់ពេលវេលា ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** បន្តជំរុញការងាររបស់ក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានទៀងទាត់ និងការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម បន្តការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីការបិទស្លាកសញ្ញាការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ព្រមទាំង បន្តការចងក្រងព័ត៌មានពាក់ព័ន្ធនិងសារធាតុញៀនថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ (NPS) ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគី ថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសអនុវត្តយន្តការភូមិ ស គ្មានគ្រឿងញៀន នៅតាមព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមក រួមទាំងកិច្ចអន្តរាគមន៍នានា ដែលមានលក្ខណៈពហុវិស័យ ក្នុងការពង្រឹង-ពង្រីកការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** តាមបណ្តោយព្រំដែនកម្ពុជា-ឡាវ / កម្ពុជា-ថៃ / កម្ពុជា-វៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយអង្គការUNODC បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជាមួយនេះ ត្រូវបន្តការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅគ្រប់ឃុំ-សង្កាត់ ដើម្បីគាំទ្រនិងជំរុញដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំ និងណែនាំជាគោលការណ៍សំខាន់ៗខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានជួបសំណេះសំណាល និងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ចំនួន **៨៨០ នាក់** ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ និងទិសដៅការងារ ដែលបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ២០១៨ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- ឯកឧត្តម អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានផ្តល់កិច្ចសម្ភាសន៍ក្រោមប្រធានបទ " ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន " នៅស្ថានីយទូរទស្សន៍បាយ័ន
- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញស្នងការនគរបាលខេត្តកំពង់ចាម ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ ស្នងការនគរបាលខេត្តក្រចេះ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច " ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ "
- សហការជាមួយស្ថានីយវិទ្យុFM ជាតិ ៩៦ Mhz អញ្ជើញអធិការនគរបាលខណ្ឌ៧មករា ខណ្ឌព្រែកព្នៅ ខណ្ឌដង្កោ ខណ្ឌជ្រោយចង្វារ ចូលរួមផ្តល់បទសម្ភាសន៍ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់ និងដំណោះស្រាយបញ្ហាគ្រឿងញៀន
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែសីហា ឆ្នាំ២០១៨ មានការចូលអានចំនួន **៤៤.១២១ ដង**
- ផ្សព្វផ្សាយឃ្លីបវីដេអូខ្លីៗស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញ

ទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**១.២. ការងារអប់រំតាមសហគមន៍**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈ វេទិកាតុមូល វេទិកាសាធារណៈ វេទិកាជួបជាមួយវិស័យឯកជន ។ល។ មានមហាជនចូលរួមទទួលសារអប់រំចំនួន **៥៩.៦៨៩** នាក់។

ក្នុងនោះ ការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តមាន ៖

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំសិក្ខាសាលាក្រោមប្រធានបទ " យើងនាំគ្នាចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីបញ្ចប់មេរោគអេដស៍នៅឆ្នាំ២០២៥ " កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានអ្នកចូលរួមប្រមាណ ៤០០ នាក់

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការជាមួយក្រុមហ៊ុន សៀវ សុផល រៀបចំវគ្គផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងគន្លឹះឆ្ពោះទៅរកភាពជោគជ័យនៃដំណើរការមុខរបរអាជីវកម្ម កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ ដែលមានអ្នកចូលប្រមាណ ៣០០នាក់ និងកៀរគរថវិកាពីសប្បុរសជនដែលស្ម័គ្រចិត្តជួយដល់មូលនិធិអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបាន ១.៩៥០ ដុល្លារ

- ក្រសួងសាធារណការ និងដឹកជញ្ជូន បានបន្តស្នើសុំឱ្យក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ ណែនាំអ្នកបើកបរកុំឱ្យប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងស្នើឱ្យមានការបិទខិត្តប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមរថយន្ត ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- ក្រសួងសុខាភិបាល បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន) ប្រចាំខែសីហានេះ មានអ្នកទៅទទួលសេវាព្យាបាលចំនួន ៨០នាក់ ស្រី ១៥នាក់

- បានបន្តការគាំទ្រចំពោះអង្គការដៃគូ ដែលបាននឹងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត។

### ២.២. ការព្យាបាល និងស្តារនីតសម្បទា

- បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹងបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញឱ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនទៅទទួលយកការព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តបន្ទាយមានជ័យ រៀបចំដំណើរទស្សនកិច្ចជូនក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដែលអញ្ជើញទៅសិក្សាស្វែងយល់លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅមណ្ឌលជីវិតថ្មីភ្នំបាក់ ខេត្តបន្ទាយមានជ័យ ។

បន្ទាប់មក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ រៀបចំសិក្ខាសាលាមួយ នៅខេត្តសៀមរាប ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតការពិភាក្សាលើប្រសិទ្ធភាពនៃការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា (អ្នកចូលរួម ៧២នាក់)

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានដឹកនាំកិច្ចប្រជុំជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីពិភាក្សាអំពីភាពជាដៃគូររវាងមន្ត្រីសុខាភិបាលជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់សម្រាប់អនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅខណ្ឌច្បារអំពៅទី១ និងច្បារអំពៅទី២ នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) នៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួនវគ្គ២ ៖

- វគ្គទី៥ នៅថ្ងៃទី១៣-១៧ ខែសីហា ឆ្នាំ២០១៨ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ១២នាក់
- វគ្គទី៦ នៅថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ២០១៨ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ១២នាក់

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

ក្នុងខែសីហានេះ កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនមានដូចខាងក្រោម ៖

- **បទល្មើសបង្ក្រាបបាន សរុប ៤៧៣ ករណី** (រួមទាំងបទល្មើសប្រើប្រាស់)

  មានការថយចុះ ១២៧ ករណី ស្មើនឹង២១.១% បើប្រៀបធៀបខែកក្កដា មាន ៦០០ករណី ។

- **ជនសង្ស័យដែលឃាត់ខ្លួន សរុប ៩០០ នាក់ ស្រី៧៤ នាក់** (រួមទាំងជនប្រើប្រាស់)

  មានការថយចុះ ៣០៣នាក់ ស្មើនឹង ២៥.១% បើប្រៀបធៀបខែកក្កដាមាន ១.២០៣ នាក់ ។

ក្នុងនោះមាន ៦ សញ្ជាតិគឺ : ខ្មែរ ៨៨១នាក់ (ស្រី ៧១នាក់) ,វៀតណាម ១០ នាក់ (ស្រី ២ នាក់), ឡាវ ១នាក់, ចិន ២នាក់, ថៃ ៤នាក់ (ស្រី ១នាក់), រុស្ស៊ី ២នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀន ចាប់យកសរុប ២៧៦គ.ក្រ ២៨៥ក្រាម ១០០មីលីក្រាម**

រួមមាន មេតំហ្វេតាមីនក្រាមម្សៅ(ICE) ១៧៣គ.ក្រ ០៩១ក្រាម ៨០០មីលីក្រាម, មេតំហ្វេតាមីនគ្រាប់ (WY) ៦៦៣ក្រាម ៣០០មីលីក្រាម, អិចស្តាស៊ី(MDMA) ១០២គ.ក្រ ៩១៤ក្រាម, ៥០០មីលីក្រាម, ហេរ៉ូអ៊ីន ១០១ក្រាម ៥០០មីលីក្រាម, កេតាមីន ១៧៧ក្រាម ៣០០មីលីក្រាម, កញ្ឆាក្រៀម **១៩៩**ក្រាម ០២០មីលីក្រាម, ដើមកញ្ឆា២៩.០១៧ក្រាម ។

- ទ្រព្យសម្បត្តិសំខាន់ៗ ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនមាន ៖ រថយន្ត ៦ គ្រឿង ម៉ូតូ ១៤៥ គ្រឿង, ប្រាក់កម្ពុជា ២.៦២៤.៤០០ រៀល, ប្រាក់ថៃ ៩៣ បាត, ប្រាក់អាមេរិក ២៥៣ ដុល្លារ, ប្រាក់វៀតណាម ៣០០.០០០ដុង ។

**ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖**

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៣៩៦ករណី** ឃាត់ខ្លួនជនសង្ស័យ **៧១៣**នាក់ (ស្រី ៤៧នាក់)

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៧៧ករណី** ឃាត់ខ្លួនជនសង្ស័យ **១៨៧នាក់** (ស្រី ២៧នាក់)

– ជនសង្ស័យចាប់តាមដីកា មាន ៦ ដីកា ចាប់បានជនសង្ស័យ ៦ នាក់ (ប្រុស) ។

### ៣.៣. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

– សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែសីហា ឆ្នាំ២០១៨ មាន **៣១២ ករណី** ស្មើនឹង **៣៣២សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន = **៣៣០សំណាក** (៩៩,៣៨%) គឺ :
  - ➢ មេតំហ្វេតាមីនគ្រាប់ (WY) ១០សំណាក = ៣,០១%
  - ➢ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣០៦សំណាក = ៩២,១៦%
  - ➢ កេតាមីន ០៤សំណាក = ១,២០%
  - ➢ នីមេតាហ្សេប៉ាម ០២សំណាក = ០,៤២%
  - ➢ អិចស្តាស៊ី(MDMA) ០៩សំណាក = ២,៧១%
- **សំណាកអវិជ្ជមានសារធាតុញៀន = ០២សំណាក** (០,៦០%) ។

- បានផ្តល់តេស្តរកសារជាតុញៀនមេតំហ្វេតាមីនក្នុងទឹកនោម ៥.៦០០ តេស្ត, តេស្តរកសារជាតុញៀន អិចស្តាស៊ី(MDMA) ៦០០ តេស្ត, ម៉ាគ្វីតេស្ត ៤.០៩០ តេស្ត, ម៉ាគ្វីតេស្ត ៥០០ មិល្លីលីត្រ

- បានផ្តល់ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន ៣៥០ សន្លឹក ដល់អង្គភាពចំនួន ១១ គឺ មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កំពង់ចាម, ត្បូងឃ្មុំ, កំពង់ស្ពឺ, កណ្តាល, សៀមរាប, បន្ទាយមានជ័យ, តាកែវ និងខេត្តស្ទឹងត្រែង ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រួតពិនិត្យសារជាតុញៀន ក្នុងតារាងឧសម្ពន្ធ័ទី២ ទី៣ និងសារជាតុគីមីផ្សំក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងខែសីហា ឆ្នាំ២០១៨នេះ សរុបចំនួន **៤៦.៩១០** គ.ក្រ **៩០** ក្រាម ក្នុងនោះ ៖

– ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានផ្តល់អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដាប្រើប្រាស់សារជាតុគីមី ចំនួន ៧.៩៦០ គ.ក្រ

– ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់អាជ្ញាប័ណ្ណ ចំនួន ៣៨.៩៥០ គ.ក្រ

– ក្រសួងសុខាភិបាល ផ្តល់អាជ្ញាប័ណ្ណ ចំនួន ៩០ ក្រាម

– ក្រសួងសុខាភិបាល នាំចូលសារជាតុញៀនក្នុងតារាងឧបសម្ពន្ធ័ទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន ៩៧ គ.ក្រ ៥៥៥ ក្រាម ១៧៧ មិល្លីក្រាម ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ១រូប ចូលរួមកិច្ចប្រជុំអាស៊ានរបស់ក្រុមការងារត្រួតពិនិត្យគ្រឿងញៀនតាមកំពង់ផែសមុទ្រ លើកទី៣ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ពីថ្ងៃទី១៤-១៧ ខែសីហា ឆ្នាំ២០១៨ នៅខេត្តឈុនបូរី ប្រទេសថៃ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់បញ្ជូនមន្ត្រី ចូលរួមកិច្ចប្រជុំស្តីពីកម្មវិធី Air cargo លើកទី១ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ពីថ្ងៃទី ១៣-១៧ ខែសីហា ឆ្នាំ២០១៨ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

– អគ្គលេខាធិការ អ.ជ.ប.គ.ញ. និងសហការីបានចូលរួមកិច្ចប្រជុំស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ នៅសាលារាជធានីភ្នំពេញ

– អគ្គលេខាធិការ អ.ជ.ប.គ.ញ. និងសហការីបានចូលរួមកិច្ចប្រជុំដើម្បីត្រួតពិនិត្យសភាពការណ៍គ្រឿងញៀនវិវត្តន៍ថ្មីៗនាពេលបច្ចុប្បន្ន និងការពង្រឹងការអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ នៅសាលាខេត្តព្រះសីហនុ

– បន្តជំរុញការអនុវត្តផែនការភូមិ ស គ្មានគ្រឿងញៀន នៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ ឡាវ

– បាននិងកំពុងរៀបចំខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

– បាននិងកំពុងរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

# IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៨

ដើម្បីអនុវត្តបន្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ (ឆ្នាំ២០១៨) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បាន បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅការងារសម្រាប់**ខែកញ្ញា ឆ្នាំ ២០១៨** ដូចខាងក្រោម ៖

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់ទេសចរណ៍របស់រាជធានី-ខេត្ត គ្រឹះស្ថានសិក្សា និងបណ្តារោងចក្រនានា ។

**១.២.** ត្រៀមចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ របស់រាជរដ្ឋាភិបាល នៅស្ថានីយទូរទស្សន៍ហង្សមាស ។

**១.៣.** បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញស្នងការនគរបាលកំពង់ធំ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងស្នងការនគរបាលតាកែវ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ។

**១.៤.** បន្តសហការជាមួយស្ថានីយវិទ្យុFM ជាតិ 96 Mhz អញ្ជើញ នាយប៉ុស្តិ៍ ៖ នគរបាលប៉ុស្តិ៍រដ្ឋបាលប្រាំងចំរេះ១, នគរបាលប៉ុស្តិ៍រដ្ឋបាលគីឡូម៉ែតលេខ៦, នគរបាលប៉ុស្តិ៍រដ្ឋបាលទួលសង្កែ១ និងនគរបាលប៉ុស្តិ៍រដ្ឋបាលទួលសង្កែ២ ចូលជាវាគ្មិនផ្តល់បទសម្ភាសន៍ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់ និងដំណោះស្រាយបញ្ហាគ្រឿងញៀន ។

**១.៥.** បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និង NICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

**១.៦.** បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

**១.៧.** បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅលើក្រុមគោលដៅជាសិស្សានុសិស្ស ។

**១.៨.** បន្តជំរុញនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ធ្វើសកម្មភាពផ្សព្វផ្សាយអប់រំជាមួយវិស័យឯកជន និងក្រុមហ៊ុន ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើ សមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

**២.១.** បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

**២.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចាត់បញ្ជូនមន្ត្រី ១រូប ចូលរួមវគ្គបណ្តុះបណ្តាលការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលរៀបចំដោយអគ្គនាយកដ្ឋានសេវាឱសថ នៃក្រសួងសុខភាពសាធារណៈថៃ ពីថ្ងៃទី០៣-១៤ ខែកញ្ញា ឆ្នាំ២០១៨ ប្រទេសថៃ ។

**២.៣.** ជំរុញនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាបព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**២.៤.** បន្តជំរុញការរៀបចំគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលនិងស្តារនីតិសម្បទា នៅតាម ឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**២.៥.** បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.៦.** បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

**២.៧.** បន្តចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**២.៨.** ត្រៀមចុះត្រួតពិនិត្យមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់រដ្ឋ និងឯកជន ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តកិច្ចសហការជាមួយអង្គការUNODC ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនង(**BLO**)ថ្មី កម្ពុជា-វៀតណាម ចំនួន ២ នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (ខេត្តកំពត) ។

**៣.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ(CBT) និងតាមប្រព័ន្ធអេឡិចត្រូនិច(e-Learning) ចំនួន៥វគ្គ។

**៣.៣.** ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាម

ព្រំដែននៃច្រកទ្វារនីមួយៗ ។

**៣.៤.** ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែអន្តរជាតិ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

**៤.១.** បន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារជាតុគីមីផ្សំដែលជាវត្ថុធាតុដើម ព្រមទាំងសារធាតុញៀនផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ ។

**៤.២.** បន្តសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី រោងចក្រ សហគ្រាស ឱ្យមានការយល់ដឹងពីសារធាតុគីមីផ្សំដែលអាចបង្វែរយកទៅផលិតជាគ្រឿងញៀនខុសច្បាប់ ។

**៤.៣.** បន្តសិក្សាស្រាវជ្រាវប្រមូលព័ត៌មានដែលពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ថ្ងៃទី០៣-០៦ ខែកញ្ញា ឆ្នាំ២០១៨ នៅខេត្តសៀមរាប ។

**៥.២.** បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ ២០១៧-២០១៨ ។

**៥.៣.** បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា-ថៃ-ឡាវ រយៈពេល ២ ឆ្នាំ (២០១៧ -២០១៨) ។

**៥.៤.** ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី ថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** អគ្គលេខាធិការ អ.ជ.ប.គ.ញ. ត្រៀមដឹកនាំប្រតិភូកម្ពុជា ទៅចូលរួមក្នុងកិច្ចប្រជុំ ថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣៩ ស្តីពីបញ្ហាគ្រឿងញៀន ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនប្រ៊ុយណេ (BKN) ពីថ្ងៃទី២៧-៣០ ខែសីហា ឆ្នាំ២០១៨ នៅប្រទេសប្រ៊ុយណេ ។

**៦.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចាត់បញ្ជូនមន្ត្រី ២រូប ទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី UNODC Global SMART Programme Regional ប្រចាំតំបន់ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) ពីថ្ងៃទី២៨-៣០ ខែសីហា ឆ្នាំ២០១៨ នៅខេត្តឈៀងរ៉ៃ ប្រទេសថៃ ។

**៦.៣.** ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមទៅចូលរួមកិច្ចប្រជុំ ADLOMICO លើកទី២៨ ស្តីពីបញ្ហាគ្រឿងញៀន ដែលរៀបចំដោយការិយាល័យអគ្គរដ្ឋអាជ្ញាសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ ។

**៦.៤.** ត្រៀមចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន។

៦.៥. ត្រៀមចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៦ ស្តីពីបញ្ហាគ្រឿងញៀន ។

៦.៦. ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋាន (AAITF) ។

៦.៧. បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងUNODC សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន និងគាំទ្រដល់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បន្តណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

៧.២. បន្តការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ឆ្នាំ២០១៨។

៧.៣. បន្តការរៀបចំខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៤. បន្តការរៀបចំនីតិវិធីដាក់បញ្ចូលស្លឹករុក្ខជាតិខាត (KHAT) ទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៥. អគ្គលេខាធិការ អ.ជ.ប.គ.៣. និងសហការីត្រៀមចូលរួមកិច្ចប្រជុំដើម្បីត្រួតពិនិត្យសភាពការណ៍គ្រឿងញៀនវិវត្តន៍ថ្មីៗ នាពេលបច្ចុប្បន្ន និងការពង្រឹងការអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ខុសច្បាប់ លើកទី៣ នៅសាលាខេត្តសៀមរាប ។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ មាស-វីរិទ្ធ

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ជួន សុវណ្ណ អនុប្រធាន អ.ជ.ប.គ.៣.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣.
  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ